**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខ: ០០៥/១៨ សរប.អពប

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្ដីព្រាងច្បាប់ ស្ដីពីវិសោធនកម្មមាត្រា៨៧ ចំណុចជើងចំណុច «គ» នៃផ្នែកទី៣ ជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្ដីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧**

**២- សេចក្ដីព្រាងច្បាប់ ស្ដីពីប្រាក់ឈ្នួលអប្បបរមា**

**៣- សេចក្ដីព្រាងច្បាប់ ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ស្ដីពីសញ្ជាតិខ្មែរដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧**

**៤- គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព៧០០ មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០មេហ្គាវ៉ាត់ នៅខេត្តកំពង់ស្ពឺ**

**៥- បញ្ហាផ្សេងៗ៖**

ក្រោយពីបានស្ដាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្ដូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចអនុម័ត៖

**១- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច «គ» នៃផ្នែកទី៣ ជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧**

ការកែសម្រួលបញ្ញត្តិមាត្រា៨៩ ស្តីពីការទូទាត់ប្រាក់បំណាច់បណ្តេញចេញនិងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីការងារ គឺក្នុងគោលបំណងរក្សាផលប្រយោជន៍ជូនទាំងកម្មករនិយោជិត ទាំងនិយោជក និងរាជរដ្ឋាភិបាល។ ការធ្វើវិសោធនកម្ម មានដូចខាងក្រោម៖

- បង្ការហានិភ័យរបស់កម្មករនិយោជិត ជាពិសេសក្នុងករណីរោងចក្រ សហគ្រាសបិទទ្វារដោយម្ចាស់រត់ចោល ដោយទទួលបានការទូទាត់ប្រាក់បំណាច់អតីតភាពការងារជារៀងរាល់៦ខែម្តង ផ្អែកតាមអតីតភាពការងារ ដោយមិនមានកំណត់កម្រិតអតិបរិមានៃប្រាក់បំណាច់អតីតភាពការងារ បើទោះបីជាកម្មករនិយោជិតត្រូវបានបញ្ឈប់ ឬលាឈប់ពីការងារ
- សម្រាលបន្ទុកនិយោជកក្នុងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ជៀសវាងការរក្សាទុកប្រាក់បំណាច់អតីតភាពរហូតដល់ពេលបញ្ចប់កិច្ចសន្យា
- លើកកម្ពស់ភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ដោយកាត់បន្ថយការតវ៉ាទាមទារការទូទាត់ប្រាក់បំណាច់ផ្សេងៗ ក៏ដូចជាការកាត់បន្ថយការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមដោះស្រាយជាមួយម្ចាស់រោងចក្រ សហគ្រាស ក្នុងករណីម្ចាស់រោងចក្រសហគ្រាស រត់ចោលកម្មករនិយោជិតជាយថាហេតុ។

សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការងារមាន៣មាត្រា៖

- មាត្រា១ ចែងអំពីការធ្វើវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច "គ" នៃផ្នែកទី៣ ជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារ
- មាត្រា២ ចែងអំពីការគណនាប្រាក់បំណាច់អតីតភាពការងារមុនច្បាប់នេះចូលជាធរមាន
- មាត្រា៣ ចែងអំពីការអនុវត្តច្បាប់នេះជាការប្រញាប់។

**២- សេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា**

ការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិតវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតផលស្បែកជើង បានអនុវត្ត១៣លើករួចមកហើយដែលធ្វើឱ្យប្រាក់ឈ្នួលអប្បបរមាបានកើនឡើងពី ៤០ដុល្លារនៅឆ្នាំ១៩៩៧ មកដល់១៧០ ដុល្លារនៅឆ្នាំ២០១៨។

ស្ថិតក្នុងបរិបទប្រកួតប្រជែងដ៏ខ្លាំងក្លា ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិនៅក្នុងតំបន់ ការគ្រប់គ្រងលើតម្លៃពលកម្មដ៏សមស្របមួយ គឺជាចំណុចអាទិភាពដែលប្រទេសកម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់ជាចាំបាច់បំផុត។ ការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា គឺពិតជាមានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស។

សេចក្តីព្រាងច្បាប់នេះមានគោលបំណង និងគោលដៅ៖

- លើកកម្ពស់ជីវភាពរស់នៅសមរម្យ ថ្លៃថ្នូរ បង្កើតឱកាសការងារ និងបង្កើនផលិតភាពរបស់កម្មករនិយោជិត
- ជំរុញឱ្យមានបរិយាកាសវិនិយោគ និងធុរកិច្ចកាន់តែប្រសើរប្រកបដោយភាពទាក់ទាញ

- ធានាការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បង្កើតនីតិវិធីកំណត់ប្រាក់ឈ្នួលអប្បបរមាតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច
- បង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដើម្បីជាយន្តការត្រីភាគីសម្រាប់សិក្សាស្រាវជ្រាវ និងផ្តល់អនុសាសន៍អំពីប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗរបស់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើសហគ្រាសឬគ្រឹះស្ថាន និងជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

សេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមានេះ មាន៦ ជំពូក និង៣០ មាត្រា គឺជាសមិទ្ធផលថ្មីមួយទៀតក្នុងការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា។

**៣- សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១១ មាត្រា១២ ចំណងជើងជំពូកទី៤ មាត្រា១៦ មាត្រា១៩ មាត្រា២៦ មាត្រា៥០ មាត្រា៥១ មាត្រា៥២ មាត្រា៥៣ មាត្រា៥៤ មាត្រា៥៥ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦៥ មាត្រា៦៦ មាត្រា៦៧ និងមាត្រា៦៨ នៃច្បាប់ ស្តីពីស្តង់ដាកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧**

ការធ្វើវិសោធនកម្មនេះ គឺសំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីស្តង់ដាកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពផលិតផល សេវាកម្ម និងការគ្រប់គ្រង បង្កើនប្រសិទ្ធភាពផលិតកម្មឱ្យកាន់តែប្រសើរឡើង ធានាឱ្យការធ្វើពាណិជ្ជកម្មមានលក្ខណៈត្រឹមត្រូវ និងងាយស្រួល បង្កើនការការពារអ្នកប្រើប្រាស់ លើកកំពស់សេវាសាធារណៈ ប្រឆាំងរាល់ផលិតផលក្លែងបន្លំ និងគ្មានគុណភាពដែលបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព និងសុវត្ថិភាព មនុស្ស សត្វ និងបរិស្ថាន និងកិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់ និងអន្តរជាតិ ឱ្យស្របទៅនឹងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងដើម្បីបំពេញបន្ថែមបទប្បញ្ញត្តិដូចខាងក្រោម៖

- ផ្តល់នីតិសម្បទាដល់មន្ត្រីអធិការកិច្ចរបស់វិទ្យាស្ថានស្តង់ដាកម្ពុជាឱ្យទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ និង នីតិវិធីនៃការធ្វើអធិការកិច្ច ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីស្តង់ដាឱ្យមានប្រសិទ្ធភាពខ្ពស់
- បង្កើតឱ្យមានយន្តការនៃការពិន័យអន្តរការណ៍ចំពោះការប្រព្រឹត្តបទល្មើសទៅនឹងច្បាប់នេះដោយក្នុងនោះ កែសម្រួលឱ្យមានការបែងចែកកម្រិតដាក់ទោសទណ្ឌដែលជាប្រភេទបទល្មើសតូចតាចឱ្យទទួលទោសពិន័យជាទឹកប្រាក់ ដោយមិនកំណត់ជាទោសជាប់ពន្ធនាគារលើរាល់ប្រភេទបទល្មើសនោះទេ។

**៤- គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គីសនីដុតធ្យូងថ្មអានុភាព៧០០ មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គីសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០មេហ្គាវ៉ាត់ នៅខេត្តកំពង់ស្ពឺ ។**

គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព៧០០ម៉េហ្គាវ៉ាត់ តាមប្រព័ន្ធ (BOO) សាងសង់ធ្វើម្ចាស់អាជីវកម្ម មានតម្លៃវិនិយោគសរុប ១,២៩០.៥៤ លានដុល្លារអាមេរិក សម្រាប់រយៈពេលសម្បទានអាជីវកម្ម៣៥ឆ្នាំ និងទី២.គម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព ៦០ម៉េហ្គាវ៉ាត់ តាមប្រព័ន្ធ (BOO) មានតម្លៃវិនិយោគសរុប៥៨.២២៥.៣២០ដុល្លារអាមេរិក សម្រាប់រយៈពេលសម្បទានធ្វើអាជីវកម្ម២០ឆ្នាំ។

ដើម្បីកាត់បន្ថយអតុល្យភាពនៃប្រភពផ្គត់ផ្គង់ថាមពលពីវារីអគ្គិសនី នៅរដូវវស្សា និងនៅរដូវប្រាំង និងដើម្បីបំពេញបានទៅនឹងសេចក្ដីត្រូវការប្រើប្រាស់ស្របតាមកំណើននៃការរីកចម្រើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកំណើនសេដ្ឋកិច្ចជាតិ ចាំបាច់ត្រូវអភិវឌ្ឍរោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មស្អាតនេះឡើង ដោយអនុលោមតាមកម្រិតបច្ចេកទេសទំនើបជៀសវាងផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន។

ដោយឡែក គម្រោងវិនិយោគអភិវឌ្ឍសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ គឺជាប្រភេទថាមពលកកើតឡើងវិញពីធម្មជាតិមួយដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងបណ្ដាប្រទេសលើពិភពលោក គាំទ្រយ៉ាងខ្លាំង និងជំរុញលើកទឹកចិត្តវិនិយោគិនក្នុង និងក្រៅប្រទេស ធ្វើការវិនិយោគនូវថាមពលកកើតឡើងវិញនេះឱ្យបានកាន់តែច្រើនថែមទៀត។

ការអភិវឌ្ឍថាមពលអគ្គិសនីពីគ្រប់ប្រភព គឺក្នុងគោលបំណងចូលរួមកាត់បន្ថយភាពក្រីក្រ និងបង្កើតសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ រាជរដ្ឋាភិបាលបានជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទបន្តទៀត ដើម្បីធ្វើយ៉ាងណាសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រចំនួនពីរ គឺ ទី១-ដល់ឆ្នាំ២០២០ ភូមិទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងមានអគ្គិសនីប្រើប្រាស់ពីប្រភពអគ្គិសនីផ្សេងៗ និងទី២-ដល់ឆ្នាំ២០៣០ យ៉ាងហោច៩០ភាគរយនៃគ្រួសារទាំងអស់នៅទូទាំងប្រទេស នឹងមានអគ្គិសនី ដែលមានគុណភាពដូចអគ្គិសនីពីខ្សែបណ្ដាញជាតិប្រើប្រាស់។

ហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់រួចហើយ បានផ្ដល់លទ្ធភាពឱ្យព្រះរាជាណាចក្រកម្ពុជា អាចធ្វើការផ្គត់ផ្គង់អគ្គិសនីឱ្យភូមិចំនួន ១១,៥៥៨ ភូមិ ត្រូវជា ៨១.៥៨% នៃចំនួនភូមិសរុបរបស់ប្រទេសកម្ពុជារួចហើយ។ បច្ចុប្បន្នការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីគ្រប់ប្រភេទខាងលើ កំពុងតែដំណើរការទៅយ៉ាងសកម្ម ឈានទៅផ្គត់ផ្គង់ឱ្យបានគ្រប់ភូមិទាំងអស់ទូទាំងប្រទេសនៅឆ្នាំ ២០២០ តាមផែនការ។

**៥- បញ្ហាផ្សេងៗ៖**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានណែនាំរដ្ឋបាលសាធារណៈគ្រប់ជាន់ថ្នាក់ និងគ្រប់វិស័យ បន្តជំរុញការយកចិត្តទុកដាក់ឱ្យបានកាន់តែសកម្មថែមទៀតក្នុងការបម្រើសេវាសាធារណៈឱ្យបានល្អ សំដៅបំពេញឱ្យបាននូវសេចក្ដីត្រូវការជាក់ស្ដែងជូនប្រជាពលរដ្ឋ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅវេលាម៉ោង ១១ និង៥៥នាទី។ ✓

**ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២**

**រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី២៥ ខែឧសភា ឆ្នាំ២០១៨**